# វប្បធម៌ នៃឧត្តមភាព

ការធ្វើត្រាប់ ឬ អនុកម្ម តាមគំរូអ្វីមួយ ជាវត្ថុក្ដី ជាគំនិតក្ដី វាជាស្នាដៃបែបណា ? បើសិនជា ការចម្លង វាដូចគំរូបេះបិទ គេទុកអនុករនោះ ជា សិប្បករ ឬ សិល្បករ ឬ បញ្ញាជនពូកែ តែស្នាដៃរបស់គាត់ គ្មានបន្ថែមតម្លៃនោះទេ ព្រោះតម្លៃទាំងអស់វាស្ថិតនៅក្នុងវត្ថុ ឬ គំនិតដើម ដែលជាគំរូតែប៉ុណ្ណោះ។ ជាការពិត ស្នាដៃរបស់អនុករនោះ វាគ្រាន់តែជាអនុស្នាដៃគ្មានអត្តព្រលឹងសុវិចិត្រ។ ដូចយ៉ាង គ្រូពេទ្យពូកែ មិនមែនជាអ្នកគ្រាន់តែមានចំណេះដឹង នៃវិទ្យាសាស្ត្រវេជ្ជសាស្ត្រ គឺត្រូវមានស្នាដៃចេះសម្របនឹង ស្ថានភាព និង បរិស្ថាន របស់អ្នកជំងឺថែមទៀត ទើបរបៀបព្យាបាល វាមានប្រសិទ្ធិភាព។ បើប្រសិនជាគ្រូពេទ្យនោះ គាត់គ្រាន់តែយកចំណេះដឹងរបស់គាត់មកធ្វើត្រាប់ គឺពិតគ្រាន់តែជាគ្រូពេទ្យ តែមិនមែនជាអ្នកប្រសើរនោះទេ។ ដូចបុរាណភាសិតខ្មែរ ចែងថា : ចេះដប់ពុំស្មើនឹងប្រសប់មួយ។ ដូច្នេះ បញ្ញាជន មានសញ្ញាប័ត្រ ពិតណាស់ហើយថាជាអ្នកចេះមុខវិជ្ជាណាមួយ តែមិនពិត ជាអ្នកប្រសើរនៅក្នុងការអនុវត្តន៍នោះឡើយ។ នៅក្នុងវិស័យ ដឹកនាំ គេតែងតែស្វែងរក អ្នកប្រសើរជានិច្ច។ លទ្ធិប្រជាធិបតេយ្យ ដែលអនុញ្ញាតឱ្យមានការជ្រើសរើសអ្នកប្រសើរក្នុងចំណោមពួកអ្នកពូកែ។ បើស្រុកខ្មែរគ្មានអ្នកប្រសើរ គឺច្បាស់ជាមានយួន គេជាអ្នកប្រសើរលើ ហ៊ុន សែន ដែលជាអ្នកពូកែ។ តើ សម រង្ស៊ី ជាអ្វី ? បោះឆ្នោតដោយសេរីទើបដឹងបាន។ តែក៏មានអ្នកប្រសើរជាងក្នុងចំណោមអ្នកប្រសើរសំរាប់ជ្រើសយក។ នេះជា វប្បធម៌ នៃឧត្តមភាព៕